California's Protection & Advocacy System

# ប្រាក់ទិញអាហារសម្រាប់អ្នកទទួលជំនួយពី SSI!

*April 2019, Pub#7142.06 - Cambodian*

ក្នុងឆ្នាំ 2019 ពលរដ្ឋដែលទទួលបានជំនួយពី SSI អាចទទួលបានប្រាក់ច្រើនជាងមុនរៀងរាល់ខែ សម្រាប់ទិញអាហារបរិភោគ! សូមអានខ្លឹមសារខាងក្រោម សម្រាប់ព័ត៌មានបន្ថែម!

## តើខ្ញុំអាចទទួលបានប្រាក់ច្រើនជាងមុនសម្រាប់ទិញអាហារតាមរបៀបណា?

មានកម្មវិធីមួយហៅថា CalFresh ដែលគេតែងហៅថា Food Stamps ។ ចាប់ពីថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2019 ពលរដ្ឋដែលទទួលបានជំនួយពី SSI នឹងមានសិទ្ធិអាចទទួលបានជំនួយ CalFresh ដែរ ។

## តើការផ្តល់ប្រាក់ជំនួយនេះ នឹងដំណើរការយ៉ាងដូចម្តេច?

កម្មវិធី CalFresh ផ្តល់ប្រាក់ឲ្យអ្នករៀងរាល់ខែ សម្រាប់ចំណាយលើការទិញអាហារ ។ បើអ្នកមានលក្ខណៈសម្បត្តិអាចទទួលបានជំនួយនេះ កម្មវិធី CalFresh នឹងផ្តល់ឲ្យអ្នកនូវប័ណ្ណឥណពន្ធពិសេស ដែលហៅថាប័ណ្ណ EBT ដែលមានដាក់ប្រាក់ចូលក្នុងនោះរួចជាស្រេច ។ អ្នកអាចប្រើប័ណ្ណឥណពន្ធ EBT នោះ សម្រាប់ទិញអាហារបរិភោគ ។

## តើបរិមាណប្រាក់ជំនួយ SSI របស់ខ្ញុំនឹងថយចុះដែរឬទេ?

ទេ! បើអ្នកទទួលបានប្រាក់ជំនួយ SSI ហើយចាប់ផ្តើមទទួលបានប្រាក់ជំនួយពី CalFresh ទៀត បរិមាណប្រាក់ជំនួយ SSI របស់អ្នកមិនអាចថយចុះបានទេ ។ មានន័យថា ជាមួយនឹងកម្មវិធី CalFresh គឺអ្នកនឹងទទួលបានប្រាក់ដាក់ចូលក្នុងប័ណ្ណឥណពន្ធ EBT ដែលអ្នកអាចយកវាទៅប្រើដើម្បីទិញអាហារបរិភោគ ។ ដូច្នេះ អ្នកអាចចំណាយប្រាក់ក្នុងសែក SSI ទៅលើរបស់សំខាន់ផ្សេងៗទៀត ដូចជាថ្លៃជួលផ្ទះ ជាដើម ។

## តើខ្ញុំនឹងទទួលបានប្រាក់ពី CalFresh ចំនួនប៉ុន្មាន?

វាអាស្រ័យលើស្ថានភាពនីមួយៗ ។ នៅពេលអ្នកដាក់ពាក្យសុំជំនួយ បុគ្គលិករបស់កម្មវិធី នឹងសួរអ្នក ថាតើអ្នករស់នៅជាមួយមនុស្សប៉ុន្មាននាក់ ហើយគេនឹងសម្រេចថា តើអ្នកគួរទទួលបានប្រាក់ជំនួយ CalFresh ប៉ុន្មាន ។ អ្នកអាចទទួលបានទឹប្រាក់ច្រើនជាង $100 ក្នុងមួយខែសម្រាប់ទិញអាហារបរិភោគ!

## ចុះមានការប្រែប្រួលអ្វីចំពោះគ្រួសារខ្ញុំដែរឬទេ?

បើគ្រួសាររបស់អ្នកបានទទួលប្រាក់ជំនួយ CalFresh រួចរាល់ហើយ ទឹកប្រាក់សរុបដែលអ្នក និងគ្រួសារអ្នកទទួលបានពី CalFresh អាចកើនឡើង ឬថយចុះ ។ អ្នកត្រូវសួរនាំបុគ្គលិកកម្មវិធី សម្រាប់ព័ត៍មានបន្ថែម ។

## ចុះបើអត្ថប្រយោជន៍ដែលគ្រួសារខ្ញុំទទួលបានត្រូវថយចុះ តើត្រូវធ្វើបែបណា?

បើគ្រួសារអ្នកមានសិទ្ធិទទួលបានប្រាក់ជំនួយ CalFresh នៅមុនថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2019 ហើយប្រាក់ជំនួយ SSI របស់អ្នក បានធ្វើឲ្យ
អត្ថប្រយោជន៍របស់ពួកគេថយចុះ យើងខ្ញុំនឹងវាយតម្លៃគ្រួសាររបស់អ្នក
ថាតើមានសិទ្ធិអាចទទួលបានជំនួយពីកម្មវិធីអត្ថប្រយោជន៍បង្គ្រប់
ឬអត្ថប្រយោជន៍អាហារូបត្ថម្ភអន្តរកាល (Supplemental or Transitional Nutrition Benefits) ដែរឬទេ ។ នេះជាប្រាក់ជំនួយសម្រាប់អ្នកដែល
រស់នៅជាមួយអ្នកដែលទទួលបានជំនួយពី SSI និងអ្នកដែលទទួលជំនួយពី CalFresh នៅមុនពេលដែលអ្នកទទួលជំនួយ SSI មានសិទ្ធិទទួលបានជំនួយនេះ ។ បើអ្នកទទួលជំនួយ SSI ធ្វើឲ្យអត្ថប្រយោជន៍របស់គ្រួសារអ្នកថយចុះ
ឬបាត់បង់
ខោនធីនឹងផ្តល់ប្រាក់ជំនួយបន្ថែមដល់គ្រួសារអ្នកសម្រាប់ទិញអាហារបរិភោគតាមរយៈកម្មវិធី អត្ថប្រយោជន៍បង្គ្រប់ ឬអត្ថប្រយោជន៍អាហារូបត្ថម្ភអន្តរកាល ។

អត្ថប្រយោជន៍បង្គ្រប់ និងអត្ថប្រយោជន៍អាហារូបត្ថម្ភអន្តរកាល
គឺសម្រាប់ជួយតែគ្រួសារដែលទទួលបានប្រាក់ជំនួយ CalFresh មុនថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2019 ប៉ុណ្ណោះ។ ដូច្នេះ បើអ្នកគិតថា មនុស្សក្នុងគ្រួសារអ្នក អាចមានសិទ្ធិទទួលបានប្រាក់ជំនួយ CalFresh តែនៅមិនទាន់ទទួល
បានជំនួយនេះនៅឡើយ អ្នកអាចប្រាប់ឲ្យពួកគេដាក់ពាក្យសុំជំនួយ CalFresh មុនថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2019 ដើម្បីធានាបានថា ពួកគេមានសិទ្ធិទទួលបាន

ប្រាក់ជំនួយពីកម្មវិធី អត្ថប្រយោជន៍បង្គ្រប់ ឬអត្ថប្រយោជន៍អាហារូបត្ថម្ភអន្តរកាល ។

## តើត្រូវដាក់ពាក្យសុំជំនួយដោយរបៀបណា?

អ្នកអាចដាក់ពាក្យសុំជំនួយតាមអនឡាញ តាមទូរស័ព្ទ ឬមកជួបយើងខ្ញុំដោយផ្ទាល់!

ដើម្បីដាក់ពាក្យសុំជំនួយតាមអនឡាញ សូមចូលមកកាន់ ៖
https://www.getcalfresh.org/?source=cdss

នេះជាវិបសៃត៍ ដែលមានបង្ហាញពីការិយាល័យផ្តល់ជំនួយ ៖
http://www.cdss.ca.gov/County-Offices

លេខទូរស័ព្ទគឺ 1-877-847-3663

## ខ្ញុំទទួលបាន CAPI ។ តើមានអ្វីផ្សេងទៀតផ្លាស់ប្តូរសម្រាប់ខ្ញុំដែរឬទេ?

អ្នកដែលទទួលបានជំនួយ CAPI (ដែលមានន័យថា កម្មវិធីជំនួយសាច់ប្រាក់សម្រាប់ជនអន្តោប្រវេសន៍ - (CAPI, Cash Assistance Program for Immigrants)) ក៏នឹងទទួលបានប្រាក់ជំនួយបន្ថែមចំនួន $10 ក្នុងមួយខែ សម្រាប់បុគ្គលម្នាក់ និងចំនួន $20 សម្រាប់អ្នកទទួលជំនួយ CAPI ជាប្តីប្រពន្ធ ផងដែរ។